Cambodian

# តើកូនរបស់ខ្ញុំត្រូវការរៀនឆ្នាំទីពីរនៅមត្តេយ្យសាលាឬទេ?



រដ្ឋាភិបាលវិចតូរីយ៉ាផ្តត់ផ្គង់ថវិកាកុមារដើម្បីឲ្យគេអាចទៅមត្តេយ្យសាលា នៅក្នុងឆ្នាំមុនពេលគេចាប់ផ្តើមចូលរៀន។

នេះគឺជាការសំខាន់ដែលកុមារត្រូវចាប់ផ្តើមចូលរៀន ពេលណាគេរៀបចំរួចស្រេចដើម្បីចូលរៀន នៅតាមបរិយាកាសដែលសមរម្យជាង។ ហេតុដូច្នេះហើយ នេះគឺជាការសំខាន់ដែលមាតាបិតាត្រូវគិតពិចារណា ថាតើពេលណាជាពេលប្រសើរបំផុតសំរាប់កូនរបស់ខ្លួនចាប់ផ្តើមចូលរៀន – ដ្បិតអីការនេះនឹងសំរេចទៅលើពេលល្អបំផុតដើម្បីចូលមត្តេយ្យសាលា។

កុមារមានសិទ្ធិរៀនឆ្នាំទីពីរនៅមត្តេយ្យសាលា ប្រសិនបើគ្រូបង្រៀនស្ទង់ប៉ាន់ទៅឃើញថាកូនរបស់លោកអ្នកមានដំណើរឃើតយ៉ាវផ្នែកធំលូតលាស់យ៉ាងតិចចំនួនពីរកន្លែង ហើយថាកុមារនឹងទទួលផលប្រយោជន៍អំពីការរៀនឆ្នាំទីពីរនៅមត្តេយ្យសាលា។ ផ្នែកដែលបានស្ទង់ប៉ាន់មានរួមទាំងការមើលថែដោយខ្លួនឯង មានសមត្ថភាពក្នុងការនិយាយស្តី និង/ឬការយល់ដឹងលើភាសា ការធំលូតលាស់លើភាពវាងវៃ (ប្រាជ្ញា) ការធំលូតលាស់ផ្នែកសង្គម និងការធំលូតលាស់ផ្នែកអារម្មណ៍។ កត្តាទាំងឡាយទៀតក៏អាចគេយកមកពិចារណាផងដែរ។

មានគោលការណ៍ជាក់លាក់សំរាប់គ្រូបង្រៀន និងមាតាបិតាសំរាប់ធ្វើតាមដើម្បីជួយគេសម្គាល់ទៅលើសេចក្តីត្រូវការរបស់កុមារ ហើយរៀបចំឲ្យមានគោលដៅសមរម្យសំរាប់កុមារ។ ស្ថានការណ៍នេះតម្រូវឲ្យមាតា/បិតា និងគ្រូបង្រៀនធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ ហើយធ្វើការទាក់ទងជាមួយគ្នាដោយចំហ។ ដោយមានការអនុញ្ញាតយល់ព្រមពីមាតា/បិតា និងការពិគ្រោះជាមួយមាតា/បិតា ជាដំបូងគ្រូបង្រៀនបំពេញការស្ទង់ប៉ាន់មួយ ហើយប្រសិនបើត្រូវការ គេអាចស្វែងរកការជំនួយផ្គត់ផ្គង់ពីអ្នកវិជ្ជាជីវៈផ្នែកធំលូតលាស់កុមារភាពដំបូង (ឧទាហរណ៍ ភ្នាក់ងារមត្តេយ្យសាលាប្រចាំទីកន្លែង) (Preschool Field Officers) រួចមកបញ្ជូនសេចក្តីថ្លែងនៃសិទ្ធិទទួលទៅឲ្យការិយាល័យប្រចាំតំបន់របស់ក្រសួង។

## សូមចងចាំ

- ពិចារណាដោយយកចិត្តទុកដាក់ អំពីពេលណាដែលកូនរបស់លោកអ្នកទំនងជារៀបចំរួចស្រេចដើម្បីចាប់ផ្តើមចូលរៀន ហើយថាតើពេលណាគឺជាពេលប្រសើរបំផុតសំរាប់កុមារទទួលយក បទពិសោធន៍ ផ្នែកមត្តេយ្យសាលា។ ប្រសិនបើលោកអ្នកមិនច្បាស់ប្រាកដទេ សូមនិយាយទៅ កាន់អ្នកឯទៀតដែលស្គាល់កូនរបស់លោកអ្នក ហើយដែលលោកអ្នកអាចទុកចិត្តទៅលើការ ប្រមាណមើលរបស់គេ។
- ទៅមត្តេយ្យសាលា ឬចូលរួមនៅក្នុងកម្មវិធីផ្តល់ព័ត៌មាន ហើយសាកសួរអំពីកម្មវិធីមត្តេយ្យសាលា។
- មុន និងបន្ទាប់ពីកូនរបស់លោកអ្នកចាប់ផ្តើមកម្មវិធីមត្តេយ្យសាលា ចែកចាយនូវកង្វល់ គំនិត និងយោបល់របស់លោកអ្នកអំពីកូនរបស់លោកអ្នកដោយចំហជាមួយគ្រូបង្រៀន។
- ប្រសិនបើលោកអ្នកត្រូវការការបញ្ជាក់ ឬព័ត៌មានបន្ថែមទៀតអំពីពេលណាគឺជាពេលប្រសើរបំផុតសំរាប់កូនរបស់លោកអ្នកទៅមត្តេយ្យសាលា សូមនិយាយទៅកាន់គ្រូបង្រៀនរបស់កូនលោកអ្នក អ្នកសម្របសម្រួលមើលថែកុមារ ឬគិលានុបដ្ឋាកមើលថែសុខភាពមាតា និងកុមារ។

ការផ្តួចផ្តើមរបស់
រដ្ឋាភិបាល
វិចតូរីយ៉ា

Victoria
The Place To Be

© Copyright Department of Education and Early Childhood Development, 2007